មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន
# របាយការណ៍ប្រចាំឆ្នាំ៖ ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងការទទួលព័ត៌មាននៅកម្ពុជា

ភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ចេញផ្សាយនូវរបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា ដែលផលិតដោយគម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា និងគម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា។ របាយការណ៍នេះអាចទាញយកតាមរយៈតំណភ្ជាប់ជា ភាសាខ្មែរ និងភាសាអង់គ្លេស។

របាយការណ៍នេះបង្ហាញពីទិដ្ឋភាពទូទៅនៃស្ថានភាពនៃសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា និងលទ្ធភាពរបស់សាធារណជនក្នុងការប្រើប្រាស់សិទ្ធិទាំងនោះ ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ ដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។ របាយការណ៍នេះមានទិន្នន័យសំខាន់ៗដែលបង្ហាញថាសិទ្ធិទាំងនេះត្រូវបានរឹតត្បិតបន្ថែមទៀតមុនការបោះឆ្នោតជាតិថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ដូចជាអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយចំនួន ៥ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាដកហូត អ្នកសារព័ត៌មាននិងអ្នកការពារសិទ្ធិមនុស្សជាច្រើនបានប្រឈមមុខនឹងការយាយីផ្លូវច្បាប់ និងការបំភិតបំភ័យ ហើយការចូលទៅកាន់គេហទំព័រព័ត៌មានមួយចំនួនត្រូវបានរាំងខ្ទប់ នៅមុនការបោះឆ្នោត ហើយការដាក់កំហិតលើខ្លួនឯងនៅតែបន្តកើនឡើង។ ទិន្នន័យនេះត្រូវបានបំពេញបន្ថែមដោយសក្ខីកម្មរបស់អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស អំពីបញ្ហាប្រឈមដែលពួកគេបានជួបប្រទះក្នុងការអនុវត្តការងាររបស់ខ្លួន នៅក្នុងបរិយាកាសដែលប្រឈមនេះ។

របាយការណ៍នេះក៏បង្ហាញពីកង្វះខាតចំពោះការអនុលោមតាមបទដ្ឋានស្តង់ដារច្បាប់អន្តរជាតិ ចំពោះច្បាប់មួយចំនួនដែលទើបអនុម័តនាពេលថ្មីៗ ដែលអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចកាត់បន្ថយ និងរឹតត្បិតមិនសមស្របនូវការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស។ របាយការណ៍នេះក៏បានផ្តល់អនុសាសន៍មួយចំនួនដល់រាជរដ្ឋាភិបាលក្នុងការចាត់វិធានការដាក់លាក់ ដើម្បីបំពេញកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន ក្នុងការការពារ និងលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។

*អំពីគម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា និងគម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា៖*

ដើម្បីចូលរួមដោះស្រាយចំពោះការរួមតូចនៃលំហសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន គម្រោងទាំងពីរបានផ្តោតលើការវិវត្តផ្នែកច្បាប់ ដើម្បីឱ្យច្បាប់ជាតិស្របតាមបទដ្ឋានស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។ គម្រោងទាំងពីរ ក៏ជំរុញឱ្យមានពហុភាព និងភាពចម្រុះនៃប្រព័ន្ធផ្សព្វផ្សាយ ដោយអនុញ្ញាតឱ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យអាចធ្វើការស៊ើបអង្កេត និងរាយការណ៍រាល់បញ្ហាដែលជាប្រយោជន៍សាធារណៈ ដោយមិនខ្លាចផលតបអវិជ្ជមានពីរដ្ឋាភិបាល និងដើម្បីធានាថាគ្រប់ស្ថាប័នរបស់រដ្ឋាភិបាល និងឯកជន ដែលមានមុខងារសាធារណៈត្រូវតែគោរពគោលការណ៍នៃការបញ្ចេញព័ត៌មានជាអតិបរមា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកអ្នកសម្របសម្រួលគម្រោងគាំពារប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅកម្ពុជា លោក ហួន ផន តាមរយៈអ៊ីម៉ែល phorn@cchrcambodia.org ឬលេខទូរស័ព្ទ ០៧០ ៧៥៧ ៨៨៤៕

**<u>ចប់</u>**

## **បណ្ណាធិការ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា "ម.ស.ម.ក" បានបង្កើតឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការលើកកម្ពស់ និងការពារលិទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS ៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (MOCT SOS-Torture Network) និង ជាសមាជិក OECD Watch ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" និងទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។